ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No ៤៧១០ MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពីការប្រគល់ភារកិច្ចបន្ថែមជូន នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១ :** ប្រគល់ភារៈកិច្ចបន្ថែមជូននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ឱ្យទទួលខុសត្រូវក្នុងការពិនិត្យ និងផ្តល់វិញ្ញាបនប័ត្រប្រភពដើមទំនិញ ទំរង់ធម្មតា (Certificate of Origin " C\O " Form N ) វិញ្ញាបនប័ត្រប្រភពដើមទំនិញ ទំរង់អា (Certificate of Origin " C\O " Form A) សំរាប់ នាំចេញទំនិញគ្រប់ប្រភេទ ទៅកាន់សហគមន៍អឺរ៉ុប ។

**ប្រការ ២ :** ការផ្តល់វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ ទំរង់ធម្មតា (C\O Form N) និងទំរង់អា (C\O Form A) ត្រូវអនុវត្តទៅតាមបែបបទ ដែលមានស្រាប់របស់ក្រសួងពាណិជ្ជកម្ម និងស្របតាមបញ្ញត្តិ ផ្សេងៗ ដែលកំណត់ដោយសហគមន៍អឺរ៉ុប ។

**ប្រការ ៣ :** បទបញ្ញត្តិទាំងឡាយណា ដែលមានន័យផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ :** អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស នាយិកាខុទ្ទកាល័យ ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស និងប្រធាននាយកដ្ឋានពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម_ប្រសិទ្ធ**

**កន្លែងទទួល:**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- គ្រប់អង្គភាពចំណុះ ក្រសួងពាណិជ្ជកម្ម
- គ្រប់ស្ថានតំណាងពាណិជ្ជកម្មកម្ពុជា ប្រចាំនៅក្រៅប្រទេស
- គ្រប់មន្ទីរពាណិជ្ជកម្ម ខេត្ត-ក្រុង
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ
- រាជកិច្ច ;